**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខៈ** ២៦២ **អយក.**អកស

ថ្ងៃ ពុធ ៧កើត ខែ មាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០២១

**ជម្រាបមក**
**លោក លោកស្រីប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត**

កម្មវត្ថុ ៖ ការអនុវត្តសេចក្តីណែនាំលេខ៨៧អយក.សណន ស្តីពី ការប្រារព្ធទិវាជាតិអំណាន ១១ មីនា ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៧។

យោង ៖ អនុក្រឹត្យលេខ១២០អនក្រ.បកស្តីពី ទិវាជាតិអំណានចុះថ្ងៃទី១៤ ខែ កញ្ញា ឆ្នាំ២០១៥។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនលោក លោកស្រីប្រធានជ្រាបថា៖ ក្រសួងអប់រំ យុវជន និងកីឡា នឹងរៀបចំកម្មវិធីប្រឡងប្រណាំង អានអត្ថបទ ស្មូតកំណាព្យ និងតែងនិពន្ធ ជ្រើសរើសជ័យលាភីថ្នាក់ជាតិចំណាត់ថ្នាក់លេខ១ ដល់លេខ៣ ទទួលពានរង្វាន់ សម្តេចតេជោ **ហ៊ុន សែន** ដើម្បីអបអរសាទរទិវាជាតិអំណាន ១១ មីនា ២០២១ ក្រោមប្រធានបទ "**អំណានក្នុងបរិបទកូវីដ-១៩**" ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម លោក លោកស្រីប្រធាន រៀបចំដំណើរការប្រឡងប្រណាំងជ័យលាភីថ្នាក់ក្រោមជាតិលេខ១ទាំងបីវិញ្ញាសា និងបញ្ជូនមកនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សាឱ្យបានមុនថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១ ជាកំណត់ (មានគំរូជូនភ្ជាប់)។

១.វិញ្ញាសាប្រឡងប្រណាំង
- ការតែងនិពន្ធ (អត្ថបទពាក្យកាព្យ ឬពាក្យរាយ) សម្រាប់សិស្សមធ្យមសិក្សាទុតិយភូមិ
- ការស្មូតកំណាព្យ សម្រាប់សិស្សមធ្យមសិក្សាបឋមភូមិ
- ការអានអត្ថបទ សម្រាប់សិស្សបឋមសិក្សា

២.កាលបរិច្ឆេទ និងទីកន្លែងប្រឡងប្រណាំង
- កាលបរិច្ឆេទប្រឡងប្រណាំងជ័យលាភីថ្នាក់ជាតិ៖ ថ្ងៃទី០៩ ដល់ទី១០ ខែមីនា ឆ្នាំ២០២១
- ទីកន្លែង៖ នៅអគាររដ្ឋបាលថ្មីរបស់ក្រសួងអប់រំ យុវជន និងកីឡា (ជាប់សាលាបឋមសិក្សាចៅពញាហុក)។
- ទំនាក់ទំនង៖ (អ៊ីម៉ែល៖ hun.lao@moeys.gov.kh/តេឡេក្រាម៖ ០១២ ៩២៨ ៦៩១)

សូម លោក លោកស្រីប្រធាន ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ

**ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**
**រដ្ឋលេខាធិការ**

អ៊ឹម គុច

**ចម្លងជូន៖**
- អគ្គនាយកដ្ឋានអប់រំ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"
- មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ នា. អកស

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh